**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ: ៥៤៧ សរណន.កសក

# សារាចរណែនាំ

## ស្តីពី

## វិធានការការពារ និង សង្គ្រោះសត្វក្នុងពេលមានគ្រោះទឹកជំនន់

យោងតាមស្ថានភាពបាតុភាពគ្រោះធម្មជាតិ ដែលបង្កឡើងដោយជំនន់ទឹកភ្លៀង ទឹកទន្លេមេគង្គ ទឹកទន្លេបាសាក់ និងទឹកទន្លេសាប បានកើនឡើងគួរឱ្យព្រួយបារម្ភ ជាពិសេសរាជធានី ខេត្តដែលនៅជាប់នឹងទន្លេ ស្ទឹង ព្រែក បឹងបួ តែងតែទទួលរងនូវផលប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ក៏ដូចជាផលដំណាំ និងសត្វគ្រប់ប្រភេទ។ ថ្មីៗនេះ យោងតាមសេចក្តីប្រកាសជូនដំណឹងស្តីពីការឆ្លើយតបគ្រោះអាសន្នទឹកជំនន់ឆ្នាំ២០១១ របស់គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ បានឱ្យដឹងថា ទឹកទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាបអាចនឹងបន្តកើនឡើងទៀត ដែលជាហេតុបង្កឱ្យមានគ្រោះមហន្តរាយដោយទឹកជំនន់។

ស្ថិតក្នុងស្ថានភាពនេះ ដើម្បីជំរុញលើការអនុវត្តវិធានការជួយសង្គ្រោះដល់សត្វគ្រប់ប្រភេទ ដែលនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងមន្ទីរកសិកម្មរាជធានី ខេត្តបាន និងកំពុងអនុវត្តមកទល់ពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការណែនាំបន្ថែមនូវវិធានការការពារ និងសង្គ្រោះសត្វដូចតទៅ÷

- ត្រៀមថ្នាំការពារ ព្យាបាល និងសម្ភារបរិក្ខារបសុពេទ្យ ឱ្យបានគ្រប់គ្រាន់សម្រាប់ចុះជួយអន្តរាគមន៍ពេលមានគ្រោះទឹកជំនន់
- ត្រូវបង្កើតក្រុមអន្តរាគមន៍បសុពេទ្យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ត្រៀមបម្រុងជន្លៀសសត្វ ដើម្បីជួយសង្គ្រោះសត្វស្ថិតក្នុងតំបន់ដែលទទួលការរងគ្រោះ
- ត្រៀមទីទួលខ្ពស់ដែលមិនលិចទឹក និងរៀបចំជម្រកសត្វ ដើម្បីរក្សាទុកសត្វនៅពេលចាំបាច់
- ជំរុញការចាក់ថ្នាំការពារជំងឺឆ្លងគោ ក្របី ដែលត្រៀមជន្លៀសទៅកាន់ទីទួលសុវត្ថិភាព
- ពង្រឹងការអនុវត្តន៍វិធានបសុពេទ្យប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងត្រូវបន្តចុះឃ្លាំមើលស្ថានភាពជំងឺសត្វឱ្យបានជាប្រចាំ
- ត្រូវស្វែងរកលទ្ធភាព និងមធ្យោបាយដោះស្រាយតាមគ្រប់រូបភាពឱ្យបានខ្លាំងក្លា ដើម្បីជួយសង្គ្រោះសត្វក្នុងពេលមានទឹកជំនន់នេះ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- ត្រូវបង្កើនការអប់រំដល់កសិករឱ្យចេះធ្វើអនាម័យ និងត្រៀមបម្រុង រក្សាទុកដាក់ទឹក និងចំណីអាហារសម្រាប់សត្វនៅទីកន្លែងឱ្យបានសមស្រប ដើម្បីប្រើប្រាស់ក្នុងពេលត្រូវការបន្ទាន់
- អប់រំ និងណែនាំដល់កសិករឱ្យត្រៀមមធ្យោបាយសង្គ្រោះ និងដឹកជញ្ជូនសត្វទៅតាមលទ្ធភាពដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន
- ជំរុញភ្នាក់ងារសុខភាពសត្វភូមិឱ្យបង្កើនការតាមដានជំងឺឆ្លងសត្វ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីផលិតកម្ម និងបសុព្យាបាលដែលនៅជិតបំផុត និងដល់បណ្តាញទទួលព័ត៌មានទាន់ហេតុការណ៍ដែលមានលេខទូរស័ព្ទ(០១២) ៨៣៣៧៩៥ (០១២) ២១៤៩៧០ និង(០១៧) ៦៧១១១១ ដើម្បីមានវិធានការទាន់ពេលវេលា
- ហាមបោះបង់ចោលសត្វងាប់គ្រប់ប្រភេទទៅក្នុងបឹង ត្រពាំង ប្រឡាយទឹក វាលស្រែ ព្រែក ទន្លេជាដើម។

ទទួលបាននូវសារាចរណែនាំនេះ លោកប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងលោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

ជាន់.សារុន

**<u>កន្លែងទទួល:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- គ្រប់សាលារាជធានី ខេត្ត "<u>ដើម្បីជូនជ្រាបជាព័ត៌មាន</u>"
- វិទ្យុ និងទូរទស្សន៍ "<u>ដើម្បីផ្សព្វផ្សាយ</u>"
- ឯកសារ-កាលប្បវត្តិ